ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៣២៤ MOC / M 2003

រាជធានីភ្នំពេញ . ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅកាន់ប្រទេសកាណាដា សំរាប់ឆ្នាំ២០០៤

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រក្រ/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងអនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលកាណាដា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការនាំចេញពីប្រទេសកម្ពុជា នូវផលិតផលវាយនភ័ណ្ឌសំរាប់នាំចូលទៅកាន់ប្រទេសកាណាដា ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៩
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

ប្រការ ១ : គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ( GSP Department ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ ត្រូវបានអញ្ជើញឱ្យចូលរួមដេញថ្លៃ តាមប្រភេទផ្សេងៗនៃកូតា ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

<u>ប្រការ</u> ២ : រោងចក្រនីមួយៗ ត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកជាអតិបរមា តែ២០% នៃបរិមាណកូតា ដែលដាក់ឱ្យដេញថ្លៃ តាមប្រភេទនីមួយៗ ដូចខាងក្រោម :

| Cat | Products Coverage | Tender Quantity (PCS) | Others |
|---|---|---|---|
| 5 | Trousers, Coveralls & Shorts<br>( All fibres Including Silk>70%&Vegatable >85% )<br>= Trousers, MB & WG | 168,598 | |
| 8 | ATHLTC,K/C, Blouses, Shirts/T/Sweat, Etc.<br>-T.Shirts<br>-Sweatshirts<br>-Athltc Swear | 168,598 | |
| 9 | <u>Underwear</u><br>-Men & Boys<br>-Women & Girls<br>-Children | 410,734 | |
| 10 | <u>Sleepwear & Bathrobes</u><br>-Pyjamas , MBWG<br>-Bathrobes , MBWG<br>-Pyjamas & Bathrobese | 246,440 | |
| 11 | Jarseys, Pullover, Cardigans & Sweaters<br>- Men & Boys<br>-Women & Girls<br>-Children | 164,294 | |
| | **Total** | **1,158,664** | |

<u>ប្រការ</u> ៣ : ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានការបញ្ជាក់ពីធនាគារ "Certified Check " ដែលមានតម្លៃស្មើនឹង ១០% នៃតម្លៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ជូនគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមា មិនគ្រប់ចំនួន ១០% នៃតម្លៃសរុបនឹងត្រូវចាត់ទុកពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។

<u>ប្រការ៤</u> : ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម Category នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុបត្រូវបានបែងចែកអស់ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426395

**ប្រការ ៥** : Quota ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ ៦** : តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវគិតយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ 0,010 មួយសេនដុល្លារអាមេរិក លើថ្លៃឯកត្តា ។

| Category | Minimum Bid (PCS) |
|---|---|
| 5 | US$ 0,1 |
| 8 | US$ 0,1 |
| 9 | US$ 0,05 |
| 10 | US$ 0,05 |
| 11 | US$ 0,05 |

**ប្រការ ៧** : ពាក្យសុំដេញថ្លៃ ត្រូវដាក់ជូនគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង អាគារលេខ ២០អា មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ដោយភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ ចំនួន ១០% នៃតម្លៃដេញថ្លៃសរុប ដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨** : កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម អាគារ 20 A ជាន់ទី ២ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ។

**ប្រការ ៩** : កាលបរិច្ឆេទឈប់ទទួលពាក្យសុំដេញថ្លៃ ត្រូវកំណត់ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៣ វេលា ម៉ោង ១៧:00 នាទី ល្ងាច ។

**ប្រការ ១០** : លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ ។

**ប្រការ ១១** : អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចទទួលយកកូតារបស់ខ្លួន ទៅប្រើប្រាស់បាន បន្ទាប់ពីបានទូទាត់តម្លៃដេញថ្លៃ ដែលនៅសេសសល់ រួចហើយ ។

**ប្រការ ១២** : អ្នកចូលរួមដេញថ្លៃ ដែលទទួលបានជោគជ័យ ត្រូវទូទាត់បញ្ចប់ទឹកប្រាក់នៅសល់ចំនួន ៩០ % នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៤ ។ ករណីខកខានមិនបានទទួលយកបរិមាណកូតារបស់ខ្លួន



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតាដែលមិនបានទទួលយកនោះ ត្រូវបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធក្នុងការមិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតាលើក ក្រោយៗ ទៀតឡើយ ។

**<u>ប្រការ</u> ១៣ :** អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវប្រគល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួនភ្លាមបន្ទាប់ពីថ្ងៃប្រកាសលទ្ធផល ។

**<u>ប្រការ</u> ១៤ :** កូតាដែលបានទទួលតាមរយៈនៃការដេញថ្លៃនេះ នឹងត្រូវបានប្រើប្រាស់សំរាប់តែឆ្នាំសារពើពន្ធ ២០០៤ ប៉ុណ្ណោះ ។

**<u>ប្រការ</u> ១៥ :** សេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ នៅក្នុងការអនុវត្តការដេញថ្លៃ គឺជាការសំរេចចុងក្រោយ ។

**<u>ប្រការ</u> ១៦ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, សមាជិកគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ផលិតករសំលៀកបំពាក់ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ចម ប្រសិទ្ធ

<u>**ចម្លងជូន**</u> :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា
-រាជកិច្ច ✓
-ទូរទស្សន៍ជាតិ - វិទ្យុជាតិ និងកាសែតជាតិ " ដើម្បីផ្សព្វផ្សាយ "
-ឯកសារ-កាលប្បវត្តិ